# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

# កិច្ចព្រមព្រៀងរវាង
# រោងចក្រ ខេមបូ យូនីសូល អិលធីឌី ជាមួយនឹង
# សហជីព និងប្រតិភូបុគ្គលិកទាំងអស់នៅក្នុងរោងចក្រ

ដោយមើលឃើញថារោងចក្រមិនមានការកុម្ម៉ង់អីវ៉ាន់ពីអ្នកបញ្ជាទិញបានធ្វើឲ្យរោងចក្រមិនមានការងារអោយកម្មករនិយោជិតទាំងអស់ធ្វើគ្រប់គ្រាន់  ដូច្នេះកម្មករនិយោជិតទាំងអស់ដែលតំណាងដោយសហជីពនិងប្រតិភូបុគ្គលិកបានឯកភាពជាមួយរោងចក្រក្នុងការព្យួរកិច្ចសន្យាការងារកម្មករផ្នែកខ្លះមានដូចខាងក្រោម៖

១. កម្មករ-និយោជិតចំនួន ១០០៧នាក់ (ស្រី ១០០៧នាក់) ក្នុងចំណោមកម្មករនិយោជិតសរុបចំនួន ១៨១២នាក់ ត្រូវព្យួរកិច្ចសន្យាការងារចាប់ពីថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០២៥ រហូតដល់ថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ២០២៥ ។ អំឡុងពេលព្យួរកិច្ចសន្យាការងារនេះ រោងចក្រនឹងផ្តល់ប្រាក់ឧបត្ថម្ភចំនួន ៤៥ ដុល្លារ។

២. រោងចក្រនឹងបើកប្រាក់ឈ្នួលលើកទី១នៃខែ កុម្ភៈ ឆ្នាំ ២០២៥រួមជាមួយនឹងប្រាក់ឧបត្ថម្ភអំឡុងពេលព្យួរ ជូនកម្មករ-និយោជិតនៅថ្ងៃទី ១៨ ខែ កុម្ភៈឆ្នាំ ២០២៥ ។

៣. រោងចក្រនឹងបើកប្រាក់ឈ្នួលលើកទី២នៃខែ កុម្ភៈ ឆ្នាំ ២០២៥រួមជាមួយនឹងប្រាក់ឧបត្ថម្ភអំឡុងពេលព្យួរ ជូនកម្មករ-និយោជិតនៅថ្ងៃទី ៤ ខែ មីនាឆ្នាំ ២០២៥ ។

ទន្ទឹមនឹងនេះដែររោងចក្រឯកភាពរក្សាប្រាក់រង្វាន់ការងារទៀងទាត់និងប្រាក់រង្វាន់ផ្ទាល់ខ្លួននៅដដែលសម្រាប់រយៈពេលនៃការព្យួរកិច្ចសន្យាការងារនេះ។

ចំពោះកម្មករនិយោជិតណាដែលមិនបានត្រលប់មកធ្វើការងារវិញតាមពេលកំណត់រោងចក្រនឹងអនុវត្តន៍តាមបទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុនក៏ដូចជាបទបញ្ញត្តិ និង ច្បាប់ស្តីពីការងារ។

**បញ្ជាក់៖** កិច្ចព្រមព្រៀងនេះមានប្រសិទ្ធិភាពចំពោះកម្មករ-និយោជិតទាំងអស់របស់រោងចក្រ ខេមបូ យូនីសូល អិលធីឌី ជាមួយនឹងនិយោជកនៃរោងចក្រ ខេមបូ យូនីសូល អិលធីឌី ចាប់ពីពេលចុះហត្ថលេខា នេះតទៅ។

(ចន្លោះទំនេរ)

ថ្ងៃព្រហស្បតិ៍ ៩កើត ខែមាឃ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅកណ្តាល ថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០២៥

ថ្នាក់ដឹកនាំសហជីព និងប្រតិភូបុគ្គលិក

អគ្គនាយកក្រុមហ៊ុន

ព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុន ខេមបូ យូនីសូល អិលធីឌី CAMBO UNISOLL LTD. KINGDOM OF CAMBODIA

កាង ម៉ូន សាន់